ស៊ុយអែត Sverige

សហភាពអឺរ៉ុប

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ការស្ទង់មតិយុវជនស្តីពីគោលនយោបាយ៖

## តើពលរដ្ឋវ័យក្មេងយល់ឃើញដូចម្តេចអំពីការអនុវត្តគោលនយោបាយរដ្ឋាភិបាលសំខាន់ៗនៅកម្ពុជា?

*ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២*

# មាតិកា

សារតារ
គោលបំណងនៃការស្រាវជ្រាវ និង
សនិទានភាព
សំណួរស្រាវជ្រាវ
វិធីសាស្ត្រស្រាវជ្រាវ
នីតិវិធីជ្រើសរើសសំណាក
កម្រងសំណួរ
ព័ត៌មានអំពីអ្នកឆ្លើយតបសម្ភាសន៍
ការរកឃើញសំខាន់ៗ
អនុសាសន៍

# សាវតារនៃការស្រាវជ្រាវ

# ប្រទេសដែលសម្បូរដោយពលរដ្ឋវ័យក្មេង...

រូប ៣.៣.២.១. ពីរ៉ាមីតអាយុប្រជាជន កម្ពុជា សរុប ឆ្នាំ២០០៨ និង ២០១៩




- បើទោះជាមានការប្រែប្រួលផ្នែកប្រជាសាស្ត្រ កម្ពុជានៅតែជាប្រទេសដែលសម្បូរទៅដោយពលរដ្ឋវ័យក្មេង

(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២០)

# ការប្រែប្រួលក្នុងចំណោមពលរដ្ឋជាយុវជន







(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២០; Eurostat ឆ្នាំ២០២០)

# របៀបដែលគោលនយោបាយរដ្ឋាភិបាល ផ្តល់ផលជះលើយុវជន

- ការវិនិយោគទៅលើយុវជនគឺជាគន្លឹះដើម្បីជំរុញភាពរីកចម្រើន (ធនាគារពិភពលោក ឆ្នាំ២០០៧)
- ការបរាជ័យផ្តោតការយកចិត្តទុកដាក់លើមនុស្សវ័យក្មេងនាំមកនូវការខាតបង់ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយដ៏ច្រើន (ធនាគារពិភពលោក ឆ្នាំ២០១០)
- គោលនយោបាយរដ្ឋាភិបាល ជាពិសេសទាក់ទងនឹងការអប់រំ ការងារ និងសុខភាពគឺមានផលជះលើយុវជន (USAID ឆ្នាំ២០១២)
- មានគម្លាតដ៏ធំរវាងគោលនយោបាយយុវជន និងការអនុវត្តគោលនយោបាយនោះ (Youth Policy Labs ឆ្នាំ២០១២)

# ក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងយុវជន

- នៅប្រទេសកម្ពុជាមាន**ក្របខ័ណ្ឌគោលនយោបាយច្រើន**ដែលមានគោលដៅធ្វើឱ្យប្រសើរឡើងនូវស្ថានភាពយុវជន

| យុទ្ធសាស្ត្រ/គោលនយោបាយ | ឆ្នាំអនុម័ត |
|---|---|
| **ក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ** | |
| យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ | ២០១៨ |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ | ២០១៨ |
| គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ | ២០១៥ |
| គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ | ២០១៤ |
| គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន | ២០១១ |
| ផែនការសកម្មភាពជាតិស្តីការអភិវឌ្ឍយុវជន | ២០១៥ |

# ក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងយុវជន

| យុទ្ធសាស្ត្រ/គោលនយោបាយ | ឆ្នាំអនុម័ត |
| --- | --- |
| **តាមវិស័យ** | |
| **អប់រំ** | |
| គោលនយោបាយជាតិស្តីពីការអប់រំក្រៅប្រព័ន្ធ | ២០០២ |
| គោលនយោបាយសាលាកុមារមេត្រី | ២០០៧ |
| គោលនយោបាយជាតិស្តីពីសុខភាពសិក្សា | ២០១៩ |
| គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ | ២០១៨ |
| គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី | ២០១៦ |

| យុទ្ធសាស្ត្រ/គោលនយោបាយ | ឆ្នាំអនុម័ត |
| --- | --- |
| **តាមវិស័យ** | |
| **សុខាភិបាល** | |
| ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ | ២០១៥ |
| គោលនយោបាយជាតិស្តីពីគុណភាពក្នុងវិស័យសុខាភិបាល | ២០០៥ |
| **ការងារ** | |
| ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ | ២០១៥ |
| គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស ២០១៧-២០២៥ | ២០១៦ |
| គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ ២០១៩-២០២៣ | ២០១៨ |
| ផែនការសកម្មភាពជាតិស្តីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ | ២០១៥ |

# គោលបំណងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ឆ្នាំ២០១១




| |
|---|
| **គោលបំណង៖** "យុវជនមានឱកាសអភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក"។ |
| គោលដៅ ១៖ ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណធម៌ និងសមធម៌។ |
| គោលដៅ ២៖ លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព។ |
| គោលដៅ ៣៖ លើកកម្ពស់យេនឌ័រប្រកបដោយសមធម៌ និងសមភាពដល់យុវជនទាំងពីរភេទ ពិសេសផ្តល់ឱកាសនិងសិទ្ធិអំណាចដល់ស្ត្រី។ |
| គោលដៅ ៤៖ អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ។ល។ |
| គោលដៅ ៥៖ បង្កឱកាសឱ្យយុវជនបានចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ។ |
| គោលដៅ ៦៖ ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ មាតាបិតាឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។ |
| *ប្រភព៖ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១១* |

# គម្លាតរវាងគោលនយោបាយ និងការអនុវត្ត

- ទោះយ៉ាងណាក៏ដោយ មាន**ភាពមិនស្របគ្នាខ្លាំងរវាងគោលនយោបាយ និងការអនុវត្ត**
- ការស្រាវជ្រាវបង្ហាញថា យុវជនកម្ពុជាជួបប្រទះ**បញ្ហាប្រឈមជាច្រើន** ជាពិសេសនៅក្នុង៖
  - ការអប់រំ
  - សុខភាព
  - ការងារ
  - ការចូលរួមផ្នែកនយោបាយ

(ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០០៩; អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ឆ្នាំ២០១៤; មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ឆ្នាំ២០១៧)

# គោលបំណងនៃការស្រាវជ្រាវ

- **វាស់ស្ទង់ចំណេះដឹង**របស់យុវជនអំពីគោលនយោបាយ និងយុទ្ធសាស្រ្តចម្បងៗរបស់រដ្ឋាភិបាល ទាក់ទងនឹងសុខភាព ការអប់រំ ការងារ និងការចូលរួមរបស់យុវជន
- **ស្វែងយល់អំពីបទពិសោធន៍ និងការយល់ឃើញ**របស់យុវជនចំពោះការអនុវត្តគោលនយោបាយយុវជន
- **ទាញយកការបកស្រាយដោយផ្អែកលើភស្តុតាង**ចំពោះគោលនយោបាយ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានាទាក់ទងនឹងសុខភាព ការអប់រំ ការងារ និងការចូលរួមរបស់យុវជន

# វិធីសាស្ត្រស្រាវជ្រាវ

- ការស្ទង់មតិដោយផ្ទាល់មុខជាមួយយុវជនចំនួន **១,៦០០នាក់** ដែលមានអាយុពី **១៥ឆ្នាំ ទៅ ៣០ឆ្នាំ**
  - ត្រូវបានជ្រើសរើសដោយចៃដន្យពី**២០០ភូមិ** ក្នុង**១០០ឃុំ** ទូទាំង**២៥រាជធានី-ខេត្ត**
- ការជ្រើសរើសដោយចៃដន្យតាមកម្រិតដែលមានបួនដំណាក់កាល
- ការប្រមូលទិន្នន័យត្រូវបានអនុវត្តដោយក្រុមហ៊ុនដែលមានបទពិសោធន៍ខ្ពស់ខាងការស្ទង់មតិ ចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១
  - ការប្រើប្រាស់កម្មវិធី និងឧបករណ៍ជំនួយក្នុងការសម្ភាស (CAPI)
- ការសម្ភាសធ្វើឡើងនៅផ្ទះរបស់អ្នកឆ្លើយតប

# វិធីសាស្ត្រពិគ្រោះយោបល់ក្នុងដំណើរការស្រាវជ្រាវ

- **គណៈកម្មការពិគ្រោះយោបល់**ត្រូវបានបង្កើតឡើងដើម្បីផ្តល់យោបល់ទៅលើគម្រោងស្រាវជ្រាវនេះ
  - សមាជិកមានចំនួន **១០រូប** ដែលអញ្ជើញមកពី**ប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នសិក្សាធិការ សង្គមស៊ីវិល សហគមន៍ម្ចាស់ជំនួយ**
- គណៈកម្មការបានផ្តល់យោបល់លម្អិតតាមជំហានសំខាន់ៗនៃដំណើរការស្រាវជ្រាវ
  - តាមរយៈ**កិច្ចប្រជុំពិគ្រោះយោបល់** និង**ការផ្ញើជាលាយលក្ខណ៍អក្សរ**

# កម្រងសំណួរស្រាវជ្រាវ

- **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន (ឆ្នាំ២០១១)** ផ្តល់នូវក្របខ័ណ្ឌគោលសម្រាប់ការរៀបចំកម្រងសំណួរ
- កម្រងសំណួរផ្តោតលើការប្រមូលព័ត៌មានអំពីចំណេះដឹង បទពិសោធន៍ ការយល់ឃើញរបស់យុវជនកម្ពុជាទៅលើគោលនយោបាយសំខាន់ៗ ដូចជា ការអប់រំ សុខភាព ការងារ និងការចូលរួមរបស់ប្រជាពលរដ្ឋ
- កម្រងសំណួរមាន **១១៣សំណួរ** ដែលត្រូវបានបែងចែកជា **១០ផ្នែក**
- ជាមធ្យម ការសម្ភាសនីមួយៗមានរយៈពេលប្រហែល **៣៥នាទី**


Generated by marady, Nov 08, 2021 20:03
Questionnaire created by marady, Oct 10, 2021 09:58
Last modified by marady, Nov 04, 2021 15:14

Not shared with anyone

Sections: 16, Sub-sections: 0,
Questions: 140.
Questions with enabling conditions: 34
Questions with validation conditions:5
Rosters: 1
Variables: 5

Survey Solutions

## ការស្ទង់មតិយុវជនកម្ពុជា ឆ្នាំ២០២១

SURVEY IDENTIFICATION INFORMATION
QUESTIONNAIRE DESCRIPTION

ទំព័រដើម
No sub-sections, No rosters, Questions: 4, Static texts: 1.

ការជ្រើសរើសអ្នកតបសម្ភាសន៍
No sub-sections, Rosters: 1, Questions: 7, Static texts: 1, Variables: 5.

ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា
No sub-sections, No rosters, Questions: 3.

ស្ថានភាពហិរញ្ញវត្ថុយុវជន
No sub-sections, No rosters, Questions: 7, Static texts: 1.

សេដ្ឋកិច្ច និងស្តង់ដាររស់នៅ និងអនាគត
No sub-sections, No rosters, Questions: 3.

ការយល់ដឹងអំពីគោលនយោបាយយុវជន
No sub-sections, No rosters, Questions: 6.

សុខភាព និងសុខុមាលភាព
No sub-sections, No rosters, Questions: 13.

វិស័យអប់រំ
No sub-sections, No rosters, Questions: 14.

ការងារ
No sub-sections, No rosters, Questions: 22.

ការចូលរួមរបស់ពលរដ្ឋ
No sub-sections, No rosters, Questions: 15, Static texts: 1.

ចំណាប់អារម្មណ៍លើនយោបាយ
No sub-sections, No rosters, Questions: 5.

ចំណាប់អារម្មណ៍រឿងនយោបាយលើបណ្តាញសង្គម

# ព័ត៌មានអំពីអ្នកចូលរួមផ្តល់សម្ភាសន៍

# ព័ត៌មានអំពីអ្នកឆ្លើយតបសម្ភាសន៍










*ស=១,៦០០នាក់

# ព័ត៌មានអំពីអ្នកឆ្លើយតបសម្ភាសន៍










*ស=១,៦០០នាក់

# ការរកឃើញសំខាន់ៗ

# ផ្នែកទី១

# ស្ថានភាពនៃការរស់នៅ

**បើប្រៀបនឹងពេល៥ឆ្នាំមុន តើអ្នកគិតថាស្ថានភាពរស់នៅរបស់អ្នកក្នុងពេលឥឡូវនេះ មានលក្ខណៈដូចម្តេច?**




**គន្លឹះសំខាន់៖** យុវជនភាគច្រើនបានមើលឃើញថា កម្រិតជីវភាពរបស់ពួកគេមានភាពប្រសើរឡើងជាងមុន។ ទោះជាយ៉ាងណាក៏ដោយ មានយុវជនមួយចំនួនបានយល់ឃើញថាកម្រិតជីវភាពរបស់ពួកគេមានសភាពនៅដដែល ឬធ្លាក់ចុះជាងមុន។

# ផ្នែកទី១

# ស្ថានភាពហិរញ្ញវត្ថុយុវជន

តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានថវិកាគ្រប់គ្រាន់សម្រាប់ថែទាំសុខភាពរបស់អ្នកពេលឈឺថ្កាត់ ?




តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនអាចរក្សាកម្រិតជីវភាពរស់នៅដូចពីមុន ?



# ផ្នែកទី១

# ស្ថានភាពហិរញ្ញវត្ថុយុវជន

### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានលុយ សម្រាប់បង់ថ្លៃការសិក្សា? (ក្នុងចំណោមអ្នកឆ្លើយតបដែលជាសិស្សនិស្សិត)




### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានលុយគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំខែ?



# ផ្នែកទី១

# ស្ថានភាពហិរញ្ញវត្ថុយុវជន

### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានថវិកាគ្រប់គ្រាន់ សម្រាប់ថែទាំសុខភាពរបស់អ្នកពេលឈឺថ្កាត់?




### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនអាចរក្សាកម្រិតជីវភាព រស់នៅដូចពីមុន?




### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានលុយ សម្រាប់បង់ថ្លៃការសិក្សា?




### តើអ្នកមានក្តីបារម្ភកម្រិតណាអំពីបញ្ហា មិនមានលុយគ្រប់គ្រាន់ សម្រាប់ការចំណាយប្រចាំខែ?




**គន្លឹះសំខាន់រួម៖** យុវជនមានការព្រួយបារម្ភអំពីការបំពេញតម្រូវការហិរញ្ញវត្ថុទូទៅប្រចាំថ្ងៃ។

# ផ្នែកទី២

# ការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗរបស់រដ្ឋាភិបាល




**គន្លឹះសំខាន់៖** ចំណេះដឹងរបស់យុវជនអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សំខាន់ៗរបស់រដ្ឋាភិបាល មានកម្រិតទាប។

# ផ្នែកទី៣

# សុខភាព និងសុខុមាលភាព

### ក្នុងមួយឆ្នាំចុងក្រោយនេះ តើការចំណាយលើសុខភាពរបស់អ្នកបាន...........?




### ភាគរយអ្នកដែលបាននិយាយថាការចំណាយលើសុខភាពរបស់ពួកគេបានកើនឡើង ដោយបែងចែកតាមកត្តាភេទ



# ផ្នែកទី៣

# សុខភាព និងសុខុមាលភាព

## ក្នុងរយៈពេល១២ខែចុងក្រោយនេះ តើអ្នកធ្លាប់ពន្យារពេលទៅទទួលការព្យាបាលដោយសារតែអ្នកពុំមានលទ្ធភាពបង់ថ្លៃព្យាបាលដែរឬទេ?




## ភាគរយអ្នកដែលបានពន្យារពេលទៅទទួលការព្យាបាល ដោយបែងចែកតាមកត្តាភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម និងតំបន់រស់នៅ




**គន្លឹះសំខាន់៖** យុវជនជាស្ត្រី អ្នករស់នៅជនបទ មានចំណូល និងកម្រិតអប់រំទាប គឺទំនងជាពន្យារពេលទៅទទួលការព្យាបាលជាងយុវជនជាបុរស អ្នករស់នៅទីប្រជុំជន មានចំណូល និងកម្រិតអប់រំខ្ពស់។

# សុខភាព និងសុខុមាលភាព

**គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គឺដើម្បីបង្កើនការផ្តល់សេវាសុខភាពសម្រាប់យុវជន។ តើអ្នកគិតថាគោលដៅនេះសម្រេចបានកម្រិតណាហើយ?**




**គន្លឹះសំខាន់៖** ភាគរយច្រើនគួរសមនៃយុវជនបានយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការពង្រឹងការផ្តល់សេវាសុខភាពសម្រាប់យុវជន នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

# ផ្នែកទី៣

# សុខភាព និងសុខុមាលភាព




**គន្លឹះសំខាន់៖** យុវជនបានចាត់ទុកសេវាកម្មមិនល្អ (រួមទាំងអំពើពុករលួយ និងការយកចិត្តទុកដាក់មិនស្មើភាពគ្នា) គឺជាបញ្ហាធំបំផុតនៅក្នុងសេវាសុខភាពសាធារណៈ បន្ទាប់មកគឺកង្វះសម្ភារៈបរិក្ខារនិងធនធានមនុស្ស និងការចំណាយខ្ពស់។

# ផ្នែកទី៤

# ការអប់រំ

**គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គឺផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានគុណភាព។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ?**




**គន្លឹះសំខាន់៖** យុវជនជាច្រើនយល់ឃើញថា រដ្ឋាភិបាលមិនទាន់បានធ្វើកិច្ចការគ្រប់គ្រាន់ក្នុងការលើកកម្ពស់វិស័យអប់រំដែលប្រកបដោយគុណភាពសម្រាប់យុវជននោះទេ។

# ផ្នែកទី៤

# ការអប់រំ

ប្រសិនបើរៀន តើអ្នកធ្លាប់ត្រូវបានគេរើសអើងដោយសារតែអត្តសញ្ញាណយេនឌ័ររបស់អ្នក(ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា) ឬភាពងាយគ្រោះរបស់អ្នក(ភាពក្រីក្រ ពិការភាព ជាតិសាសន៍) នៅអំឡុងពេលអ្នករៀនដែរឬទេ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ?




ប្រសិនបើរៀន តើអ្នកធ្លាប់ត្រូវបានគេបៀតបៀនដោយសារតែអត្តសញ្ញាណយេនឌ័ររបស់អ្នក(ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា) ឬភាពងាយគ្រោះរបស់អ្នក(ភាពក្រីក្រ ពិការភាព ជាតិសាសន៍) នៅអំឡុងពេលអ្នករៀនដែរឬទេ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ?




**គន្លឹះសំខាន់៖** យុវជនមួយចំនួនតូចបានរាយការណ៍ថាត្រូវបានគេរើសអើង ឬបៀតបៀន ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេនៅសាលារៀន។

# ផ្នែកទី៤

# ការអប់រំ

## តើអ្នកយល់ស្របកម្រិតណាជាមួយនឹងអំណះអំណាង៖ "ការអប់រំដែលខ្ញុំចង់បានគឺហួសពីលទ្ធភាពថវិការបស់ខ្ញុំ។"?




## តើអ្នកគិតថាមនុស្សម្នាក់ត្រូវមានការអប់រំកម្រិតណាទើបអាចទទួលជោគជ័យនៅក្នុងសង្គមយើង?




**គន្លឹះសំខាន់៖** យុវជនជាច្រើនមើលឃើញថាការអប់រំឧត្តមសិក្សាមានសារសំខាន់ ប៉ុន្តែត្រូវចំណាយខ្ពស់។

# ផ្នែកទី៤

# ការអប់រំ




**គន្លឹះសំខាន់៖** យោងតាមយុវជន លទ្ធភាពទទួលបាននិងបរិយាកាសសិក្សា ការចំណាយខ្ពស់ និងគុណភាពនៃការបង្រៀន ត្រូវបានចាត់ថ្នាក់ជាបញ្ហាចម្បងទាំងបី នៅក្នុងប្រព័ន្ធអប់រំសាធារណៈ។

# ផ្នែកទី៥

## ការងារ




**គន្លឹះសំខាន់៖** ការអប់រំ និងជំនាញត្រឹមត្រូវ ត្រូវបានមើលឃើញថាជាគន្លឹះក្នុងការធានាការងារក្នុងវិស័យសាធារណៈ បន្ទាប់មកគឺទំនាក់ទំនងផ្ទាល់ខ្លួននិងប្រាក់កាស ហើយនឹងបទពិសោធន៍ការងារ។

# ផ្នែកទី៥

# ការងារ




**គន្លឹះសំខាន់៖** យុវជនជាច្រើនបានគិតថា កន្លែងធ្វើការនៅកម្ពុជាមិនបានផ្តល់ឱកាសការងារគ្រប់គ្រាន់សម្រាប់យុវជនមានពិការភាព។

# ផ្នែកទី៥

# ការងារ

ប្រសិនបើមានការងារធ្វើ តើអ្នកធ្លាប់ត្រូវបានគេរើសអើងដោយសារតែអត្តសញ្ញាណយេនឌ័ររបស់អ្នក(ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា) ឬភាពងាយគ្រោះរបស់អ្នក(ភាពក្រីក្រ ពិការភាព ជាតិសាសន៍) នៅកន្លែងការងារដែរឬទេ?




ប្រសិនបើមានការងារធ្វើ តើអ្នកធ្លាប់ត្រូវបានគេបៀតបៀនដោយសារតែអត្តសញ្ញាណយេនឌ័ររបស់អ្នក(ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា) ឬភាពងាយគ្រោះរបស់អ្នក(ភាពក្រីក្រ ពិការភាព ជាតិសាសន៍) នៅកន្លែងការងារដែរឬទេ?




**គន្លឹះសំខាន់៖** យុវជនមួយចំនួនតូចបានរាយការណ៍ថា ពួកគេត្រូវបានគេរើសអើង ឬបៀតបៀន ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេនៅកន្លែងធ្វើការ។

# ផ្នែកទី៥

## ការងារ



តើអ្នកយល់ស្របកម្រិតណាជាមួយនឹងអំណះអំណាង៖
"ខ្ញុំពុំបានទទួលព័ត៌មានការងារគ្រប់គ្រាន់ទេ"?
យល់ស្របទាំងស្រុង
18.6%
យល់ស្របខ្លះៗ
54.4%
យល់ស្របផង មិនយល់ស្របផង
9.8%
មិនយល់ស្របខ្លះៗ
9.1%
មិនយល់ស្របទាំងស្រុង
3.8%
មិនដឹង/បដិសេធឆ្លើយ
4.4%

# ផ្នែកទី៥

## ការងារ

### តើអ្នកយល់ស្របកម្រិតណាជាមួយនឹងអំណះអំណាង៖ "ខ្ញុំបារម្ភថាខ្ញុំខ្វះជំនាញដែលចាំបាច់ដើម្បីទទួលបានការងារណាមួយ"?



# ផ្នែកទី៥

## ការងារ

**តើអ្នកយល់ស្របកម្រិតណាជាមួយនឹងអំណះអំណាង៖**
**“ឧបសគ្គធំបំផុតក្នុងជំនាន់ខ្ញុំគឺការស្វែងរកការងារដែលមានប្រាក់ខែល្អ”?**



# ការងារ

### គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គឺដើម្បីបង្កើនការងារសម្រាប់យុវជន។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ?




**គន្លឹះសំខាន់៖** មួយភាគធំនៃយុវជនបានគិតថា មានកិច្ចការជាច្រើនទៀតដែលអាចធ្វើបាន ដើម្បីលើកកម្ពស់ការងាររបស់យុវជននៅកម្ពុជា។

# ផ្នែកទី៥

## ការងារ

### តាមការយល់ឃើញរបស់អ្នក តើបញ្ហាធំបំផុត នៅក្នុងវិស័យការងារនៅកម្ពុជាគឺជាអ្វី?




**គន្លឹះសំខាន់៖** បញ្ហាចម្បងទាំងបីក្នុងវិស័យការងារគឺ ប្រាក់បៀរវត្សរ៍ទាប កង្វះខាតនិងភាពមិនស៊ីគ្នានៃជំនាញ និងឱកាសការងារមិនគ្រប់គ្រាន់។

## ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

### តើអ្នកបានដឹងថាអ្នកមានសិទ្ធិចូលរួមក្នុងសកម្មភាពខាងក្រោមដែរឬទេ ? ដូចជា៖




**គន្លឹះសំខាន់៖** យុវជនភាគច្រើនមិនបានដឹងពីសិទ្ធិចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាន។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

## តើអ្នកធ្លាប់បានចូលរួមសកម្មភាពខាងក្រោមដែរឬទេ? ដូចជា៖




**គន្លឹះសំខាន់៖** កម្រិតនៃការចូលរួមក្នុងមូលដ្ឋានក្នុងចំណោមយុវជនមានកម្រិតទាប។

# ការចូលរួមក្នុងសង្គម និងនយោបាយ

## Q67- ប្រសិនបើអ្នកមិនដែលបានចូលរួមក្នុងសកម្មភាពណាមួយ ឬច្រើនដែលរៀបរាប់ខាងលើ តើមូលហេតុអ្វីដែលរារាំងអ្នកមិនឱ្យចូលរួម?




**គន្លឹះសំខាន់៖** ឧបសគ្គចម្បងទាំងបីដែលរារាំងយុវជនពីការចូលរួមរួម មានដូចជា៖ ពួកគេមិនត្រូវបានអញ្ជើញ កង្វះខាតព័ត៌មាន និងភាពមមាញឹករបស់យុវជន។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ




**គន្លឹះសំខាន់៖** កម្រិតនៃការចូលរួមក្នុងសង្គម និងនយោបាយក្នុងចំណោមយុវជន មានកម្រិតទាប។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

## តើអ្នកមានការចាប់អារម្មណ៍លើរឿងនយោបាយកម្រិតណា?




## ហេតុអ្វីបានជាអ្នកមាន "ការចាប់អារម្មណ៍តិចតួច/មិនចាប់អារម្មណ៍" លើរឿងនយោបាយ?




**គន្លឹះសំខាន់៖** ការចាប់អារម្មណ៍របស់យុវជនចំពោះកិច្ចការរដ្ឋាភិបាល និងកិច្ចការសាធារណៈមានកម្រិតទាប។

**គន្លឹះសំខាន់៖** កង្វះខាតចំណេះដឹងអំពីនយោបាយ គឺជាហេតុផលចម្បងដែលរារាំងយុវជនជាច្រើនមិនឱ្យចាប់អារម្មណ៍លើនយោបាយ។ យុវជនមួយចំនួនយល់ថានយោបាយមានភាពគ្រោះថ្នាក់។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

**នៅពេលអ្នកជួបជុំជាមួយសមាជិកគ្រួសារ ឬមិត្តភក្តិ តើអ្នកពិភាក្សាគ្នាលើរឿងនយោបាយញឹកញាប់កម្រិតណា?**




**គន្លឹះសំខាន់៖** មានតែយុវជនមួយភាគតូចប៉ុណ្ណោះដែលពិភាក្សារឿងនយោបាយនៅក្នុងក្រុមគ្រួសារ ឬជាមួយមិត្តភក្តិ។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ




**គន្លឹះសំខាន់៖** យុវជនភាគច្រើនមានគណនីបណ្ដាញសង្គម។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

**តើអ្នកប្រើប្រាស់បណ្ដាញសង្គមដើម្បីបង្ហោះ ចែករំលែកបន្ត បញ្ចេញយោបល់ ឬ ពិភាក្សារឿងនយោបាយ ឬរដ្ឋាភិបាលតាមបណ្ដាញសង្គមញឹកញាប់កម្រិតណា?**




**គន្លឹះសំខាន់៖** ទោះបីជាបណ្ដាញសង្គមជាផ្នែកមួយដែលមិនអាចខ្វះបាននៃជីវិតប្រចាំថ្ងៃរបស់យុវជនក៏ដោយ មានតែចំណែកតូចមួយនៃពួកគេបានប្រើវាដើម្បីតាមដានសំណេរមតិយោបល់ ឬបង្ហាញពីទស្សនៈរបស់ពួកគេអំពីនយោបាយ។

# ផ្នែកទី៦

# ការចូលរួមក្នុងសង្គម និងនយោបាយ

**គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គឺផ្តល់ឱកាសឱ្យយុវជនអាចចូលរួមពេញលេញក្នុងការអភិវឌ្ឍប្រទេសជាតិ។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ ?**




**គន្លឹះសំខាន់៖** យុវជនជាច្រើនយល់ថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងសង្គម និងនយោបាយនៅមិនទាន់គ្រប់គ្រាន់នៅឡើយ។

# ការចូលរួមក្នុងសង្គម និងនយោបាយ

**តាមមតិរបស់អ្នក តើឧបសគ្គធំបំផុតដែលរារាំងយុវជនមិនឱ្យចូលរួម សកម្មភាពសង្គម ឬនយោបាយគឺជាអ្វី?**




**គន្លឹះសំខាន់៖** ទាក់ទងនឹងការចូលរួមក្នុងសង្គម និងនយោបាយ បញ្ហាចម្បងទាំងបីដែលយុវជនបានកំណត់ឃើញសម្រាប់ភាគីផ្គត់ផ្គង់ រួមមាន កង្វះខាតឱកាស (រួមទាំងបរិយាកាសនយោបាយមិនអំណោយផល និងកង្វះយន្តការសម្រាប់ការចូលរួម) ហើយសម្រាប់ភាគីយុវជនផ្ទាល់ រួមមាន កង្វះចំណេះដឹងអំពីការចូលរួម និងកង្វះខាតសមត្ថភាពនិងធនធានក្នុងការចូលរួម។

# ផ្នែកទី៧

# ទស្សនៈទៅលើការការខាររបស់រដ្ឋាភិបាល

ប្រសិនបើអ្នកមិនពេញចិត្ត ជាមួយសេវាសាធារណៈណាមួយ (ដូចជាសេវាថៃទាំសុខភាព ការធ្វើឯកសារនានា គុណភាពផ្លូវថ្នល់។ល។) តើអ្នកនឹងធ្វើរឿងនេះទេ៖ ដូចជាទាក់ទងទៅមន្ត្រីរដ្ឋ ឬស្ថាប័នពាក់ព័ន្ធ ឬបង្ហោះក្នុងគណនីសង្គមផ្ទាល់ខ្លួនឱ្យមានការដោះស្រាយរឿងទាំងនេះដែរឬទេ?




**គន្លឹះសំខាន់៖** យុវជនភាគច្រើនមិនមានឆន្ទៈក្នុងការលើកឡើងពីចំណុចខ្វះខាតនៅក្នុងការផ្តល់សេវាសាធារណៈ។

# ផ្នែកទី៧

# ទស្សនៈទៅលើការការងាររបស់រដ្ឋាភិបាល

## នៅពេលគិតពីអនាគត តើអ្នកគិតថាស្ថានភាពវិស័យខាងក្រោមនេះនឹងមានការប្រែប្រួលបែបណាក្នុងរយៈពេល ៥ឆ្នាំទៅមុខ ?




**គន្លឹះសំខាន់៖** យុវជនមានសុទិដ្ឋិនិយមថា សេវាសាធារណៈនឹងផ្លាស់ប្តូរកាន់តែប្រសើរឡើងក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ យុវជនច្រើនគួរសមមិនសូវមានក្តីសង្ឃឹមអនាគតនោះទេ នៅពេលនិយាយអំពីការការពារធនធានធម្មជាតិ និងបរិស្ថាន។

# ផ្នែកទី៧ ទស្សនៈទៅលើការការងាររបស់រដ្ឋាភិបាល




**គន្លឹះសំខាន់៖** ការកាត់បន្ថយអំពើពុករលួយ ការបង្កើនការងារ និងការកាត់បន្ថយភាពក្រីក្រ ត្រូវបានចាត់ថ្នាក់ជាអាទិភាពរបៀបវារៈគោលនយោបាយសម្រាប់យុវជនកម្ពុជាសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។

# អនុសាសន៍

- បង្កើនការចាប់អារម្មណ៍ ចំណេះដឹង និងការចូលរួមរបស់យុវជននៅក្នុងគោលនយោបាយសាធារណៈសំខាន់ៗ
- រៀបចំសូចនាករដើម្បីតាមដានវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន
- ធ្វើឱ្យការអប់រំថ្នាក់ឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របនឹងលទ្ធភាពហិរញ្ញវត្ថុរបស់យុវជន
- បង្កើនព័ត៌មានអំពីការងារសម្រាប់យុវជន

- លើកកម្ពស់ការងារសម្រាប់យុវជនមានពិការភាព
- អនុម័តគោលការណ៍យកចិត្តទុកដាក់ស្មើៗគ្នា និងមិនមានការរើសអើង
- លើកកម្ពស់ឱកាសទទួលបានការងារដោយស្មើភាពក្នុងវិស័យសាធារណៈសម្រាប់យុវជន
- ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសផ្នែកច្បាប់ គោលនយោបាយ និងនយោបាយនៅក្នុងប្រទេស
- ជំរុញកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់អំពើពុករលួយ និងលើកកម្ពស់អភិបាលកិច្ចល្អ។

# ឯកសារយោង


- Eurostat, *Being young in Europe today - demographic trends* (Eurostat, 2020)
- Kampuchean Action to Promote Education, *Empowering Youth in Cambodia Today: Youth Situation Analysis* (Phnom Penh: KAPE, 2014)
- Ministry of Planning, *General Population Census of the Kingdom of Cambodia 2019* (Phnom Penh: Ministry of Planning, 2020)
- OECD Development Centre, *Youth Well-being Policy Review of Cambodia, EU-OECD Youth Inclusion Project* (Paris: OECD Development Centre, 2017)
- The World Bank, *World Bank Development Report: Development and the Next Generation* (The World Bank, 2007)
- USAID, *Youth in Development Policy: Realizing the Demographic Opportunity* (Washington: USAID, 2012)
- United Nations Country Team, *Situation Analysis of Youth in Cambodia* (Phnom Penh: UNCT, 2009)
- Youth Policy Labs, *Youth Policy Reviews: Improving Public Policies for Young People Through Research and Advocacy* (Youth Policy Labs, 2012)

# សូមអរគុណ

សំណួរ និងចម្លើយ